# ព្រះរាជក្រឹត្យ

នស/រកត/១០០៤/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សត្រខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សារាជសម្បត្តិ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៤
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៦៥ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤ ស្តីអំពីការតែងតាំងឯកឧត្តម គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង ជាសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
- បានទ្រង់យល់សេចក្តីត្រូវការចំពោះមុខ

## ត្រាស់បង្គាប់

មាត្រា ១ : បង្កើតព្រះរាជលញ្ចករ ដែលមានរូបលក្ខណៈភ្ជាប់ជាមួយនេះ សំរាប់ប្រថាប់លើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យ ដែលមានព្រះហស្តលេខារបស់ព្រះមហាក្សត្រ ឬ មានហត្ថលេខារបស់ប្រមុខរដ្ឋស្តីទី តាមព្រះរាជសារប្រគល់សិទ្ធិពីព្រះមហាក្សត្រ ។

មាត្រា ២ : សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង ត្រូវទទួលភារៈចាត់ការអនុវត្ត អោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៤០៣ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០១ និង ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥៣ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០១ ត្រូវចាត់ទុកជាមោឃៈ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។



**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខៈ ០០១/០៤រ.ចប
រាជធានីភ្នំពេញ ,ថ្ងៃទី០៥ ខែវិច្ឆិកាឆ្នាំ២០០៤

រូបភាពព្រះរាជលញ្ចករ ( ចម្លាក់អណ្តែត សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
**ហត្ថលេខា និងត្រា**
**គង់ សំអុល**

ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
... តាន់